រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

003KH01A-01

អ្នកធ្វើអំណោយដោយចិត្តអំណរ



កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៣

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



កំណត់ចំណាំ :

© Project WorldReach © SEAN

ទូលសូមអោយព្រះជាម្ចាស់ធ្វើអោយមេរៀននេះ នាំអោយក្រុមជំនុំរបស់អ្នក ចេះធ្វើអំណោយដោយចិត្តអំណរ ដើម្បីលើកតម្កើងព្រះកិត្តិនាម និងសិរីរុងរឿងរបស់ព្រះអង្គ ។

ដង្វាយដប់ភាគរយ និង ដង្វាយស្ម័គ្រចិត្ត

នៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ព្រះជាម្ចាស់បានបង្គាប់ប្រជា-រាស្ត្ររបស់ទ្រង់ អោយថ្វាយដង្វាយដប់ភាគរយនៃអ្វីៗ ដែលគេរកបាន ។ អ្នកដែលគ្មានលុយ ត្រូវយកផលដំណាំ និងសត្វទៅថ្វាយព្រះជាម្ចាស់ ។ គេត្រូវថ្វាយសត្វដែលល្អឥតខ្ចោះ មិនមែនថ្វាយសត្វដែលពិការ ឬ វិកលវិការឡើយ (សេរីភាព ១២:៥, លេវីវិន័យ ២២:១៧-២៤) ។

ក្រិត្យវិន័យអំពីការថ្វាយដង្វាយដប់ភាគរយនេះ ពុំមានចែងនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មីទេ ។ តែយើងថ្វាយដង្វាយដប់ភាគរយដោយសេចក្តីស្រឡាញ់ និងស្ម័គ្រពីចិត្ត ។ បើមនុស្សដែលរស់នៅសម័យកាលសម្ពន្ធមេត្រីចាស់ ថ្វាយដង្វាយដប់ភាគរយ យើងដែលស្ថិតនៅក្នុងសម័យកាលសម្ពន្ធមេត្រីថ្មី ហើយដែលបានទទួលព្រះពរច្រើនលើសពួកគេទៅទៀតនោះ ក៏គួរតែថ្វាយដង្វាយយ៉ាងតិចណាស់ អោយបានដប់ភាគរយដែរ ។

កំណត់ចំណាំ :

បើយើងប្រកបមុខរបរជំនួញ ដង្វាយដប់ភាគរយរបស់យើង គឺ
មួយភាគដប់នៃប្រាក់ចំណូលរបស់យើង (ប្រាក់ចំណូលជាប្រាក់
ដែលបានកាត់ចំណាយចាំបាច់ សំរាប់កិច្ចការជំនួញចេញរួច
ហើយ) ។

ព្រះជាម្ចាស់ចាក់បង្ហូរព្រះពរដ៏លើសលប់ មកលើសាសន៍អ៊ីស្រា-
អែល នៅពេលដែលគេថ្វាយដង្វាយដប់ភាគរយនៃអ្វីៗដែលគេរក
បាន (ម៉ាឡាគី ៣:១០) ។ ២ កូរិនថូស ៩:៧ ចែងថា៖ « *ដ្បិត
ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណា ដែលធ្វើអំណោយដោយ
ចិត្តរីករាយ* » ។ សព្វថ្ងៃនេះ ព្រះអង្គប្រទានពរតាមរបៀបផ្សេងៗ
ដល់អ្នកជឿស្មោះត្រង់ ដែលថ្វាយដង្វាយដប់ភាគរយ ដោយ
សេចក្តីស្រឡាញ់ គឺមិនមែនដោយគេបង្ខំ (ឬដោយសារតែយើង
ត្រូវតែថ្វាយ)នោះទេ ។

ព្រះជាម្ចាស់មិនទទួលយកដង្វាយដែលយើងថ្វាយ ដោយចិត្តទើស
ទំលទេ ។ ព្រះអង្គប្រទានពរដល់អស់អ្នកដែលថ្វាយ ដោយការ
លះបង់ ។ ២ កូរិនថូស ៩:៧-១៥ បង្ហាញប្រាប់អ្នកដែលលែង
នៅក្រោមវិន័យនៃសម្ព័ន្ធមេត្រីចាស់ទៀតថា យើងត្រូវថ្វាយអ្វីៗ
ដែលចិត្តយើងបានសំរេចថ្វាយទៅព្រះអង្គ និងដែលយើងអាច
ថ្វាយ ដោយចិត្តអំណរ ។ គ្រីស្តទូតតែងតែកត់សំគាល់ឃើញអំពី
អំពីរបៀប ដែលព្រះជាម្ចាស់ធ្វើអោយសំរេចសេចក្តីចែងនៅក្នុងវគ្គ

- សូមធ្វើគំរោងថវិកាមួយ ។
- ត្រូវជួយហេរញ្ញិក ធ្វើបញ្ជីអោយបានត្រឹមត្រូវ ។
- សូមអោយហេរញ្ញិកបង្ហាញគណនីនៃចំណូល និងចំណាយ
  រៀងរាល់ខែ ។

តើនរណាជាហេរញ្ញិក ?

_____

តើនរណាជាអ្នកត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ ?

_____

កំណត់ចំណាំ :

_____

_____

_____

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- សូមអធិស្ឋានឱ្យអ្នកជឿថ្វាយដង្វាយដល់ព្រះអម្ចាស់ ដោយចិត្តអំណរ ។
- សូមទន្ទេញ ២ កូរិនថូស ៩:៦-៧ ។
- សូមបង្រៀនក្រុមជំនុំរបស់អ្នក ឱ្យដាក់ប្រាក់ដង្វាយ ដោយចិត្តសទ្ធារាល់ថ្ងៃអាទិត្យ ទុកជាផ្នែកមួយនៃការថ្វាយបង្គំ ។ សូមបង្រៀនពួកគេអំពីហេតុផលនៃការដាក់ប្រាក់ដង្វាយ ដូចមានពន្យល់ខាងលើនេះស្រាប់ ។
- សូមតែងតាំងហេរញ្ញិកម្នាក់ និងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុម្នាក់ ដោយមានការព្រមព្រៀងពីក្រុមជំនុំរបស់អ្នក ។ ហេរញ្ញិកនេះ ត្រូវចំណាយតែចំនួនទឹកប្រាក់ ដែលមានការអនុញ្ញាតពីក្រុមជំនុំប៉ុណ្ណោះ ។ សូមជ្រើសរើសមនុស្សណាដែលចេះទទួលខុសត្រូវ និងពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ។

  (មិនគួរតែងតាំងអ្នកណា ដែលខ្វះខាតខ្លាំង អោយធ្វើជាហេរញ្ញិកទេ ព្រោះកិច្ចការដែលទាក់ទងនឹងលុយកាក់ អាចនាំអោយគេធ្លាក់ទៅក្នុងសេចក្តីល្បួងបាន) ។

គម្ពីរនេះ គឺនៅពេលដែលអ្នកក្រថ្វាយដោយការលះបង់ ដោយសារស្រឡាញ់ព្រះជាម្ចាស់ និងមនុស្សឯទៀតនោះ ព្រះអង្គតែងតែធ្វើអោយគេមានភរិតជីវភាពធូរស្រាលជាងមុន ។ ព្រះអង្គមិនប្រទានអោយគេមានទ្រព្យសម្បត្តិច្រើនលើសលប់ ដែលនាំអោយគេទៅជាសៅហ្មងនោះទេ ប៉ុន្តែ ព្រះអង្គច្រើនតែប្រទានអោយគេអាចមានការងារ ដែលប្រសើរជាងមុន ព្រមទាំងអោយគេចេះចំណាយអ្វីដែលគេរកបាន ដោយឈ្លាសវៃ និងឱ្យក្រុមគ្រួសារគេមានសុខភាពកាន់តែប្រសើរឡើង ។ រីឯអស់អ្នកដែលគ្រាន់តែខិតខំអោយបានអ្វីៗពីក្រុមជំនុំ ហើយមិនថ្វាយដោយចិត្តស្រឡាញ់ព្រះជាម្ចាស់នឹងទុកអោយគេនៅក្រហូត ។



ហេតុផលមួយទៀត ដែលនាំអោយយើងមានចិត្តអំណរ គឺដោយសារយើងដឹងថា ព្រះជាម្ចាស់នឹងប្រទានរង្វាន់អោយយើងវិញ នៅលើលោកីយ៍នេះ និងនៅស្ថានបរមសុខ ដោយសារសេចក្តីសប្បុរសរបស់យើង ។

«កុំសន្សំទ្រព្យសម្បត្តិទុកសំរាប់ខ្លួន នៅលើផែនដី ជាកន្លែងដែលមានកណ្តៀរ និងច្រែះស៊ី ជាកន្លែងដែលមានចោរទម្លាយជញ្ជាំងចូលមកលួចប្លន់នោះអោយសោះ ។ ចូរប្រមូលទ្រព្យសម្បត្តិទុកនៅស្ថានបរមសុខវិញ ជាស្ថានដែលគ្មានកណ្តៀរ និងច្រែះស៊ី ជាស្ថានដែលគ្មានចោរទម្លាយជញ្ជាំងចូលមកលួចប្លន់ឡើយ ។ ដ្បិតទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ» ។ (ម៉ាថាយ ៦:១៩-២១)

ព្រះយេស៊ូមានព្រះបន្ទូលតបថា÷ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាលះបង់ផ្ទះសំបែង បងប្អូនប្រុសស្រី ឪពុកម្តាយ កូន ឬ ស្រែចំការ ព្រោះតែខ្ញុំ និង ព្រោះតែដំណឹងល្អ អ្នកនោះនឹងទទួលក្នុងពេលឥឡូវនេះមួយជាមួយរយ គឺផ្ទះសំបែង បងប្អូនប្រុសស្រី ម្តាយ កូន និង ស្រែចំការ ព្រមទាំងទទួលការបៀតបៀន ហើយក៏នឹងមានជីវិតអស់កល្បជានិច្ច នៅលោកខាងមុខថែមទៀតផង» ។ (ម៉ាកុស ១០:២៩-៣០)

កាល ល.ចង្កាន់ដៃ	សេចក្តីពិស្តារ	ចំណូល	ចំណាយ	តុល្យភាព
១៣, កក្តដា	សរុបពីទំព័រមុន	១០ ៤០០	១០ ៩៥០	១១ ៩៥០
១៥ ៣៤ចំណូល	ប្រាក់ដង្វាយ ១៦,៧,០១	១ ៧០០		១៣ ៦៥០
១៥ ៣៥ចំណូល	ដង្វាយ ១០% ១៦,៧,០១	៣ ៥០០		១៧ ១៥០
១៧ ៨៨ចំណាយ	សំរាប់លាបក្នុងព្រះវិហារ		៤០០	១៦ ៧៥០
១៨ ៨៩ចំណាយ	សំរាប់ទឹកម៉ាស៊ីន		១៥០	១៦ ៦០០
២០ ៩០ចំណាយ	សៀវភៅសំរាប់ផ្សាយដំណឹងល្អ		២០០	១៦ ៤០០
២២ ៣៦ចំណូល	ប្រាក់ដង្វាយ ២៣,៧,០១	៨០០		១៧ ២០០
២៥ ៩១ចំណាយ	សំរាប់ក្រុមផ្សាយដំណឹងល្អធ្វើដំណើរ		៥៥០	១៦ ៦៥០
២៩ ៣៧ចំណូល	ប្រាក់ដង្វាយ ៣០,៧,០១	៩០០		១៧ ៥៥០
២៩ ៣៨ចំណូល	ដង្វាយសាសនទូត	៥ ២០០		២២ ៧៥០
៣០ ៩២ចំណាយ	ប្រាក់ខែគ្រូគង្វាល		៤ ៥០០	១៨ ២៥០
៣០ ៩៣ចំណាយ	ស៊ីម៉ង់ត៍សំរាប់សំណង់		៥ ២០០	១៣ ០៥០
៣១ ៩៤ ចំណាយ	អំណោយជូនគ្រួសារសាន់		១ ៤០០	១១ ៦៥០
សរុបដំណាច់ខែ		**២២ ៥០០**	**២៣ ៣៥០**	**១១ ៦៥០**
	តុល្យភាពដំណាច់ខែមុន ៣០,៦,០១	១២	៥០០	
	ចំណូលសំរាប់ខែកក្តដា	២២	៥០០	
	ចំណូលសរុប	៣៥	០០០	
	ចំណាយសំរាប់ខែកក្តដា	២៣	៣៥០	
	តុល្យភាពដំណាច់ខែកក្តដា ឆ្នាំ ០១	១១	៦៥០	

ហត្ថលេខារបស់ហេរញ្ញិក _____

ហត្ថលេខារបស់អ្នកត្រួតពិនិត្យ _____

© Project WorldReach © SEAN

មានរបៀបរៀបចំបញ្ជីចំណូលចំណាយច្រើនយ៉ាង ។ នៅទំព័រ
បន្ទាប់នេះ ជាឧទារហណ៍មួយ ។

បញ្ជីត្រាក់ : កាលបរិច្ឆេទ : ខែ កក្កដា ឆ្នាំ ២០០១

ក្រុមជំនុំអ្នកគង្វាលល្អ ។

កាល	ល.បង្គាន់ដៃ	សេចក្តីពិស្តារ	ចំណូល	ចំណាយ	តុល្យភាព
		តុល្យភាពខែមុន ៣០/៦/០១			១២ ៥០០
១/កក្កដា	៣០ចំណូល	ប្រាក់ដង្វាយ ២/៧/០១	១ ០០០		១៣ ៥០០
១	៣១ចំណូល	ដង្វាយ ១០% ២/៧/០១	៧ ០០០		២០ ៥០០
៣	៨២ចំណាយ	ក្រុមផ្សាយដំណឹងល្អធ្វើដំណើរ		៤៥០	២០ ០៥០
៦	៨៣ចំណាយ	សំរាប់អគ្គីសនី ខែមិថុនា		២០០	១៩ ៨៥០
៨	៣២ចំណូល	ប្រាក់ដង្វាយ ៩/៧/០១	១ ៣០០		២១ ១៥០
៨	៣៣ចំណូល	ដង្វាយ ១០% ៩/៧/០១	១ ១០០		២២ ២៥០
១០	៨៤ចំណាយ	អំណោយជូនអ្នកនេសាទ		១ ១០០	២១ ១៥០
១២	៨៥ចំណាយ	សំរាប់បេសកកម្មបង្រួបបង្រួម		៤ ០០០	១៧ ១៥០
១២	៨៦ចំណាយ	សំរាប់ដំណើរបេសកកម្មសាសនទូត		៤ ៥០០	១២ ៦៥០
១៣	៨៧ចំណាយ	សំរាប់សំភារៈបង្ហាត់បង្រៀនគ្រូគង្វាល		៧០០	១១ ៩៥០
១៣		**ចំនួនសរុប**	**១០៤០០**	**១០៩៥០**	**១១៩៥០**

តើព្រះជាម្ចាស់សព្វព្រះហឫទ័យយ៉ាងដូចម្តេចខ្លះ អំពីការដែលយើងថ្វាយដង្វាយ ?

១- អ្វីៗគ្រប់យ៉ាងដែលយើងមាន សុទ្ធតែជាអំណោយរបស់ព្រះជាម្ចាស់ ។

ព្រះជាម្ចាស់ជាអ្នកបង្កើត និងជាម្ចាស់លើសកលលោកទាំងមូល ។ យើងជាអ្នកចាត់ចែងទ្រព្យសម្បត្តិរបស់ព្រះអង្គ គឺ យើងត្រូវទទួលខុសត្រូវនៅចំពោះព្រះអង្គ អំពីរបៀបប្រើប្រាស់អ្វីៗ ដែលព្រះអង្គប្រទានដល់យើង ។ យើងអាចសំរេចចិត្តអោយ ដើម្បីធ្វើអោយព្រះពរបានដល់អ្នកដទៃ ឬ យើងអាចលាក់របស់ទាំងនោះទុកសំរាប់ខ្លួនឯង ដោយយើងមានចិត្តលោភលន់ ។ យើងមិនមែនជាទាសករ ដែលគ្មានសិទ្ធិសំរេចចិត្តជ្រើសរើសនោះទេ ។ ហេតុនេះហើយ បានជាព្រះអង្គសព្វព្រះហឫទ័យទទួលអ្វីៗ ដែលយើងថ្វាយដោយចិត្តអំណរ និងដោយសេចក្តីស្រឡាញ់តែប៉ុណ្ណោះ ។

ព្រះជាម្ចាស់ជាអ្នកបង្កើត និងជាម្ចាស់លើអ្វីៗទាំងអស់ ។ (កណ. ១:១, ទំនុកតម្កើង ២៤:១, ១ រាជាក្សត្រ ២៩: ១១-១៦) ។

«ព្រះអង្គដែលប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារអោយគេផងនោះ ទ្រង់ក៏នឹងផ្គត់ផ្គង់គ្រាប់ពូជអោយបងប្អូន និងអោយគ្រាប់ពូជនោះកើនចំនួនឡើងដែរ ហើយព្រះអង្គនឹងធ្វើឱ្យសេចក្តីសុចរិតរបស់បងប្អូនបង្កើតផលបានច្រើនឡើងថែមទៀត» ។ (២ កូរិនថូស ៩:១០) ។

ដោយសារតែអ្វីៗ ដែលយើងមានសុទ្ធតែបានមកពីព្រះជា-ម្ចាស់ សូមអោយយើងថ្វាយដង្វាយដប់ភាគរយនៃអ្វីៗ ដែលយើងបានទទួលនោះទៅព្រះអង្គវិញ ទោះបីជាយើងជាអ្នកក្រ ឬអ្នកមានក៏ដោយ ។

«ដង្វាយមួយភាគដប់ទាំងអស់ គឺភោគផលដែលកើតចេញពីដី ឬ ផ្លែឈើក្តី ត្រូវទុកជាសក្ការៈថ្វាយព្រះអម្ចាស់» ។ (លេវីវិន័យ ២៧:៣០)

«ហេតុនេះ ម្នាក់ៗត្រូវតែចូលប្រាក់ តាមតែខ្លួនសំរេចចិត្ត ដោយមិននឹកស្តាយ ឬ ទើសទ័លឡើយ ជ្រិតព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណា ដែលធ្វើអំណោយដោយចិត្តរីករាយ» (២ កូរិនថូស ៩:៧) ។ យើងត្រូវថ្វាយទៅព្រះអង្គនូវអ្វីដែលព្រះអង្គប្រទានដល់យើង ។

ឧទាហរណ៍នៃថវិកាមួយ :

ចំណូលដែលអាចទទួលបាន	
ដង្វាយដប់ភាគរយ	១០ ០០០
ដង្វាយស្ម័គ្រចិត្ត	៥ ០០០
ដង្វាយសំរាប់គ្រីស្តទូតធ្វើការនៅបរទេស	៥ ០០០
ចំណូលសរុបដែលអាចទទួលបាន	២០ ០០០
ចំណាយប្រចាំខែដែលបានព្រមព្រៀងហើយ	
ប្រាក់ខែគ្រូគង្វាល កិច្ចការគ្រីស្តទូតចេញផ្សាយដំណឹងល្អ	១៣ ០០០
គំរោងការជួយអ្នកខ្វះខាត	២ ០០០
ការផ្សព្វផ្សាយដំណឹងល្អ និងបង្កើតក្រុមជំនុំថ្មី	២ ០០០
កម្មវិធីបណ្តុះបណ្តាលគ្រូគង្វាល	១ ០០០
ការជួសជុល	៥០០
ចំណាយទូទៅ : អគ្គីសនី ទឹក ឧស្ម័ន	៥០០
ផ្សេងៗ	៥០០
ថវិកាសរុបប្រចាំខែ	**១៩៥០០**

កាលបរិច្ឆេទ _____ ហត្ថលេខា _____

ថវិកាក្រុមជំនុំ

«ក្នុងចំណោមអ្នករាល់គ្នា ប្រសិនបើនរណាម្នាក់ចង់សង់ផ្ទះថ្មីធំមួយ អ្នកនោះត្រូវអង្គុយគិតគូរមើលថ្លៃសង់ជាមុនសិន ដើម្បីឱ្យដឹងថា តើខ្លួនមានប្រាក់លុមនឹងបង្ហើយសំណង់ ឬយ៉ាងណា ?»។ (លូកា ១៤:២៨)

ហេរញ្ញិករបស់ក្រុមជំនុំ ត្រូវរៀបរាប់អំពីរបាយការណ៍ហិរញ្ញវត្ថុជូនគណៈកម្មាធិការក្រុមជំនុំ (ដោយរៀបរាប់អំពីតុល្យភាពកន្លងមក ចំណូលចំណាយ និងតុល្យភាពថ្មី) រៀងរាល់ខែ ។ ហេរញ្ញិកត្រូវចំណាយតែចំនួនទឹកប្រាក់ ដែលគណៈកម្មាធិការរបស់ក្រុមជំនុំអនុញ្ញាតអោយចាយប៉ុណ្ណោះ ។ ក្រុមជំនុំត្រូវប៉ាន់ប្រមាណដង្វាយដប់ភាគរយ និងដង្វាយស្ម័គ្រចិត្ត ដែលអាចនឹងទទួលបានសំរាប់ខែនិមួយៗ រួចគណៈកម្មាធិការ ត្រូវអនុញ្ញាតអោយហេរញ្ញិករបស់ក្រុមជំនុំចំណាយថវិកា ដែលបានព្រមព្រៀងគ្នាហើយ សំរាប់ខែនោះ ។ ការចំណាយផ្សេងទៀត ក្រៅពីថវិកានេះ ត្រូវមានការយល់ព្រមពីកិច្ចប្រជុំពិសេសមួយរបស់ក្រុមជំនុំ ឬគណៈកម្មាធិការក្រុមជំនុំ ។

អ្វីៗដែលយើងមាន ជារបស់ :

☐ យើងតែម្នាក់គត់ ។

☐ ព្រះជាម្ចាស់ ។

«ផែនដី និងអ្វីៗសព្វសារពើនៅលើផែនដី សុទ្ធតែជាកម្មសិទ្ធិរបស់ព្រះអម្ចាស់» ។ (ទំនុកតម្កើង ២៤:១)

ការដាក់ដង្វាយដប់ភាគរយ ជាសេចក្តីបង្គាប់នៅក្នុងក្រិត្យវិន័យព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ។ ដូច្នេះ ហេតុអ្វីបានជាបច្ចុប្បន្ននេះ យើងត្រូវថ្វាយដង្វាយដប់ភាគរយដែរ ? ក្នុងនាមជាគ្រីស្តបរិស័ទ យើងមិនមែនថ្វាយដង្វាយដប់ភាគរយដោយសារតែក្រិត្យវិន័យបង្ខំនោះទេ គឺយើងថ្វាយដោយសេចក្តីស្រឡាញ់ ដើម្បីសំរេចកិច្ចការរបស់ព្រះអម្ចាស់ នៅពេលសព្វថ្ងៃនេះ ។

សូមអាន និង រិះគិតពីព្រះបន្ទូលនៅក្នុងម៉ាឡាគី ៣:៦-១២ ។

☐ សូមគូសសញ្ញា «✓» នេះ នៅក្នុង «☐ » នៅពេលដែលអ្នកបានអាន និង រិះគិតរួចហើយ ។

សាសន៍អ៊ីស្រាអែលជំនាន់ដើមបានបះបោរ មិនស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយមិនព្រមថ្វាយដង្វាយដប់ភាគរយ ទៅព្រះអង្គវិញទេ ។ ព្រះអង្គបានព្រមានពួកគេតាមរយៈព្យាការីម៉ាឡាគីថា÷

«តើមនុស្សកេងប្រវ័ញ្ចព្រះជាម្ចាស់ដូចម្តេចបាន ? អ្នករាល់គ្នាកេងប្រវ័ញ្ចយើង ហើយពោលថា÷ "យើងខ្ញុំកេងប្រវ័ញ្ចព្រះអង្គដូចម្តេចខ្លះ ?" ។ គឺអ្នករាល់គ្នាកេងប្រវ័ញ្ចដង្វាយមួយភាគដប់ និងដង្វាយដែលអ្នករាល់គ្នាត្រូវញែកទុកសំរាប់យើង ! អ្នករាល់គ្នាត្រូវបណ្តាសាហើយ ! ព្រោះប្រជាជាតិទាំងមូល បានកេងប្រវ័ញ្ចយើង» ។ (ម៉ាឡាគី ៣:៨-៩)

«សូមចងចាំថា អ្នកណាព្រោះតិច អ្នកនោះក៏ច្រូតបានផលតិចដែរ ។ រីឯអ្នកដែលព្រោះច្រើនបរិបូណ៌ ក៏ច្រូតបានទាំងមូលបានកេងប្រវ័ញ្ចយើង» ។ (ម៉ាឡាគី ៣:៨-៩)

តើយើងច្រូតបានផលច្រើនបរិបូណ៌យ៉ាងដូចម្តេច ?ព្រះជាម្ចាស់មិនធានាថា អោយយើងមានទ្រព្យសម្បត្តិហ្វូរហៀរនៅលើផែនដីនេះទេ ។ នៅក្នុងបទគម្ពីរអេភេសូរ ១:៣ ព្រះអង្គសន្យាថា នឹងប្រទានព្រះពរគ្រប់យ៉ាង ផ្នែកខាងវិញ្ញាណពីស្ថានបរមសុខមកអ្នកជឿ ។

៣- ហិបមានសោ : ប្រាក់ដង្វាយទាំងអស់ ត្រូវដាក់នៅក្នុងហិបដែលមានសោចាក់ ។

៤- គណនីធនាគារ : ត្រូវដាក់ប្រាក់ដង្វាយមួយភាគធំទៅក្នុងគណនីនៃធនាគារ ។

៥- អ្នកត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ : ប្រហែលជាមួយខែម្តង មនុស្សម្នាក់ ដែលមិនជាប់ទាក់ទងនឹងកិច្ចការហិរញ្ញវត្ថុ ត្រូវត្រួតពិនិត្យយ៉ាងទៀងទាត់ លើរបាយការណ៍ចំណាយចំណូល បញ្ជីតុល្យភាពរបស់ធនាគារ និងរាប់ចំនួនប្រាក់ដែលនៅនឹងដៃ ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ពីតុល្យភាព ដែលមាននៅក្នុងសៀវភៅបញ្ជីចំណូលចំណាយអោយបានត្រឹមត្រូវ ។

ការគ្រប់គ្រងប្រាក់ដង្វាយ

ក្រុមជំនុំត្រូវរៀបចំអោយមានបញ្ជីចំណាយចំណូល ដែលមានរបៀបរៀបរយ ហើយហេរញ្ញិកត្រូវតែមានចិត្តស្មោះត្រង់ ។

វិធីត្រឹមត្រូវប្រាំយ៉ាង សំរាប់ជួយអោយមានការស្មោះត្រង់ និងការពារពីការល្បួង គឺ :

១- ហត្ថលេខាពីរ : យ៉ាងតិចណាស់ ក៏ត្រូវមានមនុស្សពីរនាក់សំរាប់រាប់ប្រាក់ដង្វាយ និងចុះហត្ថលេខាលើបង្កាន់ដៃ ទទួលប្រាក់ដង្វាយនោះដែរ ។

២- បង្កាន់ដៃប្រាក់ដង្វាយ : ចំពោះ «ចំណូល» និង «ចំណាយ» ត្រូវកត់ត្រាចូលក្នុងបញ្ជីគណនី ។ បង្កាន់ដៃសំរាប់ «ចំណូល» និង «ចំណាយ» ផ្សេងៗ ត្រូវតែរក្សាទុកដោយត្រឹមត្រូវ ។បង្កាន់ដៃចំណូលត្រូវមានលក្ខណៈខុសពីបង្កាន់ដៃចំណាយ ដើម្បីឱ្យមានភាពច្បាស់លាស់មែនទែន (ដូចជា ណិខុសគ្នា ឬ លេខរៀងខុសគ្នា) ។

ព្រះជាម្ចាស់សន្យាថា នឹងចំរុងចំរើន :

☐ អ្នកធ្វើអំណោយ ដោយចិត្តសប្បុរស ។

☐ អ្នកធ្វើអំណោយ ដោយទើសទំល ។

ព្រះជាម្ចាស់សព្វព្រះហឫទ័យ នៅពេលយើងធ្វើអំណោយ :

☐ ដោយចិត្តអំណរ ។

☐ ដោយនឹកស្តាយ ។

២- ព្រះជាម្ចាស់ប្រទានពរដល់យើង នៅពេលដែលយើងធ្វើអំណោយ ដោយអស់ពីចិត្ត ដោយសេចក្តីស្រឡាញ់ និងដោយចិត្តអំណរ ។

«ហេតុនេះ ម្នាក់ៗត្រូវតែចូលប្រាក់ តាមតែខ្លួនសំរេចចិត្ត ដោយមិននឹកស្តាយ ឬ ទើសទំលឡើយ ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណា ដែលធ្វើអំណោយ ដោយចិត្តរីករាយ» ។ (២ កូរិនថូស ៩:៧)

ព្រះជាម្ចាស់ទតមើលចិត្តរបស់អ្នក ដែលធ្វើអំណោយ ។ ទ្រង់មិនទទួលយកអំណោយ ដែលធ្វើដោយទើសទំលឡើយ (សេរីភាព ២៥:២) ។ ក្រិត្យវិន័យក្នុងព្រះគម្ពីរសម្ពន្ធមេត្រី

ចាស់ តំរូវឱ្យថ្វាយព្រះជាម្ចាស់ដប់ភាគរយនៃផលចំរូត ។ នៅក្នុងសម្ពន្ធមេត្រីថ្មីបច្ចុប្បន្ននេះ យើងមិនបំពេីព្រះជាម្ចាស់ដោយសារតែក្រិត្យវិន័យតំរូវនោះទេ ក៏ប៉ុន្តែ ដោយសារព្រះវិញ្ញាណនៃព្រះគ្រីស្តនៅក្នុងខ្លួនយើងវិញ ។ យើងមិនបង្ខំ ឬ គំរាមកំហែង ឬ ដាក់ទណ្ឌកម្មដល់អស់អ្នក ដែលពុំព្រមថ្វាយដង្វាយដប់ភាគរយ និងដែលមានវិញ្ញាណបះបោរ មិនស្តាប់បង្គាប់នោះឡើយ ។ ដង្វាយដប់ភាគរយរបស់គេគ្មានតំលៃអ្វីចំពោះព្រះជាម្ចាស់សោះ ។ព្រះជាម្ចាស់ទទួលយកតែដង្វាយណា ដែលគេថ្វាយដោយសេចក្តីស្រឡាញ់ប៉ុណ្ណោះ ។

៣- ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងដង្វាយ ដែលជាការលះបង់ ។

ចំពោះព្រះជាម្ចាស់ ដង្វាយដ៏តិចតួចដែលអ្នកក្រថ្វាយ អាចមានតំលៃច្រើនជាងដង្វាយដ៏ច្រើន ដែលអ្នកមានថ្វាយទៅទៀត ។ ព្រោះពួកអ្នកមានច្រើនតែថ្វាយអ្វីៗ ដែលសល់ពីការបំពេញចិត្តរបស់ពួកគេផ្ទាល់ហើយ ។ ប្រសិនបើយើងដាក់ដង្វាយតែអ្វីៗ ដែលយើងនៅសល់នោះ ដង្វាយនោះពុំសូវមានតំលៃទេ ។

បើយើងដាក់ដង្វាយ ដោយមានគោលបំណងដូចខាងក្រោមនេះក៏ជាការល្អដែរ :

- ដើម្បីឧបត្ថម្ភកិច្ចការបង្កើតក្រុមជំនុំថ្មី (ចំណាយសំរាប់ការធ្វើដំណើរ សំរាប់ឯកសារ និងសំភារៈ ។ល។) ។
- ដើម្បីបញ្ជូនជំនួយទៅទីណា ដែលមានទុរ្ភិក្ស (កិច្ចការ ១១:២៨-៣០) ។
- ដើម្បីសង់ ឬ ជួសជុលព្រះវិហារ (សេរីភាព ៣៥:២២, ២ របាក្សត្រ ២៤:១០-១៣) ។



© Project WorldReach © SEAN

មូលហេតុដែលនាំអោយយើងដាក់ដង្វាយ

ការដាក់ដង្វាយ ជាផ្នែកមួយនៃការថ្វាយបង្គំរបស់យើង«...ដោយបានទទួលអំណោយពីបងប្អូន តាមរយៈលោកអេប៉ាប្រូឌីត ។ អំណោយទាំងនេះ ប្រៀបបីដូចជាក្លិនក្រអូបឈ្ងុយឈ្ងប់ ជាយញ្ញបូជា ដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ និងយល់ព្រមទទួល» ។ (ភីលីព ៤:១៨)

នៅក្នុងក្រុមជំនុំរបស់ពួកសាវ័ក គេដាក់ដង្វាយរាល់ថ្ងៃអាទិត្យ (១ កូរិនថូស ១៦:២) ។

យើងត្រូវដាក់ដង្វាយ ដើម្បីជួយអ្នកខ្វះខាត ជាពិសេសអ្នកជឿទៀត (លូកា ១០:២៥-៣៧) ព្រមទាំងជួយឧបត្ថម្ភគ្រីស្តជនអ្នកបំរើ ដែលថ្វាយពេលវេលាទាំងអស់របស់ខ្លួន ដើម្បីបំពេញកិច្ចការបំរើ (១ ធីម៉ូថេ ៥:១៧-១៨) និងជួយចាត់គ្រីស្តទូតឱ្យទៅកន្លែងដែលមិនទាន់ឮដំណឹងល្អ ។

យើងមិនមែនចេះតែជួយមនុស្សគ្រប់គ្នា ដែលនិយាយគ្នាញឹកថា គេខ្វះខាតនោះទេ ។ បើអ្នកណាខ្ជិលមិនព្រមធ្វើការ យើងមិនជួយអ្វីទាំងអស់ (២ ថេស្សាឡូនិក ៣:១០) ។

ឧទាហរណ៍ នៅក្នុងបទគម្ពីរ លូកា ២១:១-៤ ពួកអ្នកមានខ្លះបានដាក់ដង្វាយយ៉ាងច្រើន ឯស្ត្រីមេម៉ាយដ៏ក្រីក្រម្នាក់ថ្វាយតែពីរសេនប៉ុណ្ណោះ ។ ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលថា ស្ត្រីនោះបានដាក់ប្រាក់ច្រើនជាងគេទាំងអស់ ។ តើព្រះបន្ទូលនេះមានន័យដូចម្តេច ? ស្ត្រីនោះបានដាក់ដង្វាយដែលមានភាគរយធំជាងគេ ហើយគាត់ដាក់ដង្វាយនោះដោយសេចក្តីស្រឡាញ់ ដោយលះបង់ និងដោយពុំគិតថាខ្លួនគាត់ក្រីក្រទៀតផង ។ ព្រះជាម្ចាស់មិនទតមើលតែចំនួនដង្វាយដែលយើងថ្វាយប៉ុណ្ណោះទេ គឺទ្រង់ទតមើលចិត្ត និងគោលបំណងនៃអ្នកដាក់ដង្វាយនោះផងដែរ ។





មនុស្សខ្លះ មុនដំបូងពិបាកថ្វាយដង្វាយ ដោយចិត្តសប្បុរសណាស់ ។ ប៉ុន្តែ បើគេចាប់ផ្តើមថ្វាយ ទោះជាបន្តិចក៏ដោយ



ព្រះជាម្ចាស់នឹងធ្វើការអស្ចារ្យក្នុងចិត្តគេ និងប្រទានព្រះ-ហឫទ័យប្រណីសន្តោសដល់គេ អោយគេមានចិត្តអំណរចង់ថ្វាយថែមទៀត ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងដង្វាយដែលយើងថ្វាយ ដោយចិត្តស្មោះ និងដោយស្ម័គ្រពីចិត្ត ។ ព្រះអង្គមិនសព្វព្រះហឫទ័យនឹងដង្វាយដែលយើងថ្វាយ ដោយមានពុតត្បុតទេ ។ នៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ គេថ្វាយសត្វជាយញ្ញបូជាដល់ព្រះជាម្ចាស់ ។ ព្រះអង្គគាប់ព្រះហឫទ័យតែសត្វណា ដែលល្អឥតខ្ចោះ គ្មានវិកលវិការ និងគ្មានជំងឺ (លេវីវិន័យ ៥:១៥, ១៨) ។ បើគេថ្វាយសត្វដែលមិនល្អ ដូចរៀបរាប់មកនោះ គេនឹងនាំបណ្តាសាមកដាក់លើខ្លួនគេហើយ (ម៉ាឡាគី ១:១៣-១៤) ។

ដូចគ្នានេះដែរ បើយើងថ្វាយតែអ្វីៗដែលនៅសល់ ដង្វាយរបស់យើង មិនគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ ។ ព្រះជាម្ចាស់ជាស្តេចលើអស់ទាំងស្តេច ហើយទ្រង់ជាព្រះ-អម្ចាស់នៃពិភពលោកទាំងមូល (ម៉ាឡាគី ១:១៤) ។



៤- ព្រះជាម្ចាស់មិនទទួលយកដង្វាយណា ដែលយើងថ្វាយ ដើម្បីធ្វើអោយមនុស្សស្ងើចសរសើរនោះឡើយ ។

ប្រសិនបើយើងធ្វើអំណោយ ដើម្បីឱ្យមនុស្សសរសើរ នោះគឺ យើងបានទទួលរង្វាន់រួចហើយ (ម៉ាថាយ ៦:១-២) ។ រង្វាន់ដែលយើងបានទទួលនោះ គឺការសរសើររបស់មនុស្ស។ ចូរយើងធ្វើអំណោយ ដោយស្ងាត់កំបាំង និងដោយចិត្ត សប្បុរស ដើម្បីកុំឱ្យដៃឆ្វេងដឹងថា ដៃស្តាំកំពុងធ្វើអ្វីឡើយ (ម៉ាថាយ ៦:៣-៤, រ៉ូម ១២:៨) ។

